**មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម**

**THE CENTER FOR SOCIAL DEVELOPMENT**

# ថ្ងៃបោះឆ្នោតពោរពេញដោយភាពស្ងប់ស្ងាត់ ប៉ុន្តែនៅមានភាពមិនប្រក្រតីជាច្រើន

---

## សេចក្តីប្រកាសព័ត៌មាន

---

ភ្នំពេញ, ថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៧ ៖ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម **(“ម.អ.ស.”)** សូមជំរាបថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៅអាណត្តិទី២ មានសន្តិសុខល្អ និង សណ្តាប់ធ្នាប់ទូទៅត្រឹមត្រូវ ហើយ **ម.អ.ស.** សូមសរសើរដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានបំពេញតួនាទីរបស់ខ្លួនឱ្យមានការបោះឆ្នោតប្រកបដោយសន្តិសុខ និងបរិយាកាសល្អ ។

នៅថ្ងៃបោះឆ្នោត **ម.អ.ស.** បានដាក់ពង្រាយអ្នកសង្កេតការណ៍អចិន្ត្រៃយ៍ចំនួន ១០០ នាក់ នៅក្នុងខេត្ត ក្រុងចំនួន១៥ និង អ្នកសង្កេតការណ៍ចល័តចំនួន ៥នាក់ ដើម្បីសង្កេតមើលនៅគ្រប់ការិយាល័យបោះឆ្នោតទូទាំងប្រទេស ។

ទោះជាមានបរិយាកាសស្ងប់ស្ងាត់នៅថ្ងៃបោះឆ្នោតក៏ដោយ យើងសង្កេតឃើញមានភាពមិនប្រក្រតីជាច្រើនទាក់ទិន និង ដំណើរការបោះឆ្នោតជាទូទៅ នៅតាមបណ្តាការិយាល័យបោះឆ្នោតជាច្រើន ។

ដំណើរការបោះឆ្នោត ដែលបានរៀបចំដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានប្រព្រឹត្តទៅដោយមានភាពស្មុគស្មាញជាច្រើន ដោយសារនីតិវិធីបោះឆ្នោតរបស់ គ.ជ.ប.

មិនទាន់បានសម្រួលដល់អ្នកបោះឆ្នោតនៅឡើយ ។

មានអ្នកបោះឆ្នោតជាច្រើនមិនបានទទួលប័ណ្ណព័ត៌មាន ដែលផ្ដល់ដោយ គ.ជ.ប. ។ ហើយអ្នក ដែលទទួលបានប័ណ្ណពត៌មានរួចហើយ រកទីតាំង និង លេខកូដការិយាល័យបោះឆ្នោតមិនឃើញ ។ ប្រជាពលរដ្ឋខ្លះទៀតទទួលបានប័ណ្ណព័ត៌មាននៅក្នុងដៃ ក៏ប៉ុន្តែរកឈ្មោះមិនឃើញនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត ។ គណៈកម្មការការិយាល័យបោះឆ្នោតមិនយល់ អំពីនីតិវិធីបោះឆ្នោត និងមានភាពព្រងើយកន្តើយក្នុងការរកឈ្មោះ និង លេខកូដការិយាល័យបោះឆ្នោតជូនប្រជាពលរដ្ឋ ដែលមកបោះឆ្នោត ។ ឈ្មោះ និង ថ្ងៃ ខែ ឆ្នាំកំណើតនៅក្នុងបញ្ជីឈ្មោះបោះឆ្នោតខុសគ្នាពីអ្វីដែលមាននៅក្នុងប័ណ្ណព័ត៌មាន និង ឈ្មោះ ខ្លះទៀតជាន់គ្នា ដោយហេតុនេះហើយធ្វើឱ្យអ្នកបោះឆ្នោតមានការធុញទ្រាន់ ក៏ត្រឡប់ទៅផ្ទះដោយមិនបានបោះឆ្នោត ។

ក្នុងការិយាល័យបោះឆ្នោត ជាច្រើនមានចំនួនអ្នកទៅបោះឆ្នោតតិចជាងចំនួនអ្នកបានទៅចុះឈ្មោះ បើប្រៀបធៀបទៅនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងអាណត្តិទី១ មានចំនួនថយចុះច្រើនណាស់ ។ យោងទៅតាមព័ត៌មានបណ្ដោះអាសន្នរបស់ គ.ជ.ប. អ្នកបានទៅបោះឆ្នោតមានចំនួន ៦៥% នៃអ្នកបោះឆ្នោតទាំងអស់ចំនួន ៧,៨ លាននាក់ ដែលបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត ។

អាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ មេភូមិ ក្រុមប្រឹក្សាឃុំ ឈរនៅខាងក្រៅ និង ខាងក្នុងការិយាល័យបោះឆ្នោត ក្នុងរង្វង់ការហាមឃាត់ ធ្វើឱ្យអ្នកបោះឆ្នោតមានការភ័យខ្លាច ។

គណៈកម្មការការិយាល័យបោះឆ្នោតខ្លះ មិនអនុញ្ញាតឱ្យអ្នកសង្កេតការណ៍ **ម.អ.ស.** ចូលសង្កេតក្នុងការិយាល័យបោះឆ្នោត ទោះបីជាអ្នកសង្កេតការណ៍ទាំងនោះ មានប័ណ្ណសង្កេតការណ៍ដែលបានផ្ដល់ឱ្យដោយ គ.ជ.ប. ក៏ដោយ ។

ក្នុងកំឡុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត អ្នកសង្កេតការណ៍ **ម.អ.ស.** ចំនួន ១០៥នាក់ បានសង្កេតឃើញភាពមិនប្រក្រតី រួមមាន ៖

## ១- ក្នុងពេលបោះឆ្នោត

- គណៈកម្មការការិយាល័យបោះឆ្នោតជាច្រើនរូប ពុំទាន់បានយល់ច្បាស់អំពីនីតិវិធី

បោះឆ្នោតនៅឡើយ

- ក្នុងការិយាល័យបោះឆ្នោតមានភាពរញេរញ៉ៃ គ្មានសណ្ដាប់ធ្នាប់
- គណៈកម្មការការិយាល័យបោះឆ្នោតពុំបានរកឈ្មោះជូនប្រជាពលរដ្ឋ ដែលមកបោះឆ្នោត
- គណៈកម្មការការិយាល័យបោះឆ្នោតប្រើទូរស័ព្ទដៃក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត
- គណៈកម្មការការិយាល័យបោះឆ្នោតប្រាប់លេខរៀង និង រូបសញ្ញាគណបក្សនយោបាយដល់ប្រជាពលរដ្ឋ
- កងកម្លាំងប្រដាប់អាវុធ ប៉េអឹម ប៉ូលីស ឈរនៅក្នុងរង្វង់ហាមឃាត់ ខាងក្រៅនៃការិយាល័យបោះឆ្នោត
- មេភូមិ និង ក្រុមប្រឹក្សាឃុំ ឈរក្នុងការិយាល័យបោះឆ្នោត
- មានអ្នកស្លៀកពាក់ខោ ឬ អាវ ជាទាហ៊ាន មកបោះឆ្នោត
- គណៈកម្មការការិយាល័យបោះឆ្នោតបដិសេធមិនឱ្យប្រជាពលរដ្ឋបោះឆ្នោត ដោយគ្រាន់តែខុសអក្ខរាវិរុទ្ធ
- ឈ្មោះអ្នកបោះឆ្នោតជាន់គ្នានៅក្នុងបញ្ជីបោះឆ្នោត
- អ្នកមានប័ណ្ណព័ត៌មាន ប៉ុន្តែគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត
- អ្នកមានប័ណ្ណព័ត៌មាន រកទីតាំង និង លេខកូដការិយាល័យបោះឆ្នោតមិនឃើញ
- អ្នកបោះឆ្នោតជាច្រើននាក់កាន់ប័ណ្ណពត៌មានទៅបោះឆ្នោត ដោយសារពុំបានទទួលការអប់រំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយពី គ.ជ.ប. ។
- គណៈកម្មការការិយាល័យបោះឆ្នោតបានអនុញ្ញាតឱ្យអ្នក ដែលពុំមានសិទ្ធិបោះឆ្នោតជ្រលក់ម្រាមដៃក្នុងដបទឹកខ្មៅលប់មិនជ្រះ
- ក្នុងការិយាល័យបោះឆ្នោតជាច្រើន មានអ្នកទៅបោះឆ្នោតតិចជាងចំនួនអ្នក ដែលបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត
- គណៈកម្មការការិយាល័យបោះឆ្នោតមិនអនុញ្ញាតឱ្យ អ្នកសង្កេតការណ៍ **ម.អ.ស.** ចូលសង្កេតក្នុងការិយាល័យបោះឆ្នោត ។

## ២- ក្នុងពេលរាប់សន្លឹកឆ្នោត

- ភ្នាក់ងារការពារសន្តិសុខរបស់ គ.ជ.ប. បានឈរតាមមាត់បង្អួច មើលការរាប់សន្លឹកឆ្នោត
- គណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត មិនបានបិទលទ្ធផលបណ្តោះអាសន្ន នៅមុខការិយាល័យរាប់សន្លឹកឆ្នោត និងមិនបានឱ្យអ្នកសង្កេតការណ៍គណបក្សនយោបាយចុះហត្ថលេខា លើលទ្ធផលក្នុងកំណត់ហេតុ ។
- ការរាប់ និង ការបង្ហាញសន្លឹកឆ្នោតនៅមុខអ្នកសង្កេតការណ៍គណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និង អន្តរជាតិ មានសកម្មភាពលឿនពេក ។

ព័ត៌មានបន្ថែមសូមទាក់ទង ៖

- កញ្ញា **សេខ ធារី** នាយិកាប្រតិបត្តិ ០១២ ២២២ ៥៥២
- លោកបណ្ឌិត **ហ្រ្វង់ស្វរ អ៊ឹម** ប្រធានអង្គភាពបោះឆ្នោត និង សភា ០១២ ៣៧៦ ៣០១
- លោក **អ៊ឹម សុភា** ជំនួយការប្រតិបត្តិ ០១៦ ៨៨៨ ៥៥២

---

**<u>អំពីមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម</u>**

មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម **(“ម.អ.ស.”)** ជាអង្គការមិនមែនរដ្ឋាភិបាល និង មិនរកកម្រៃ ដែលបានបង្កើតឡើងនៅភ្នំពេញតាំងពីឆ្នាំ១៩៩៥ (បានទទួលស្គាល់ដោយទីស្តីការគណៈរដ្ឋមន្ត្រីក្នុង ឆ្នាំ១៩៩៥ និង ក្រសួងមហាផ្ទៃក្នុងឆ្នាំ២០០១ ) ដើម្បីលើកតម្កើងលទ្ធិប្រជាធិបតេយ្យ និងជំរុញឱ្យមានការរីកចំរើនដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ ។

តួនាទីរបស់ **ម.អ.ស.** គឺជំរុញឱ្យមានការចូលរួមពីខាងក្រៅ (ទាំងថ្នាក់ជាតិ និងទាំងថ្នាក់មូលដ្ឋាន) នៅក្នុងកិច្ចការសាធារណៈជំរុញឱ្យមានការគោរពសិទ្ធិមនុស្ស នីតិរដ្ឋ តម្លាភាព សុច្ចរិតភាព នៅក្នុងវិស័យសាធារណៈ និងផ្សព្វផ្សាយអំពីបញ្ហាជាតិតាមរយៈ សារព័ត៌មាន

ទាំងឡាយ ។ **ម.អ.ស.** មានអង្គភាពសំខាន់ៗចំនួន ៥ ដែលកំពង់បំពេញសកម្មភាព និង គំរោង ២ ថ្មីទៀត ដែលកំពង់បំពេញតួនាទីទាំងនេះ ៖ ១- អង្គភាពច្បាប់ ២- អង្គភាពអភិបាលកិច្ចល្អ ៣- អង្គភាពវេទិកាសាធារណៈ ៤- អង្គភាពបោះឆ្នោត និង សភា ៥- អង្គភាពស្រាវជ្រាវ និង បោះពុម្ពផ្សាយ ៦- គំរោង I-Reach នៅក្រុងកែប ៧- កម្មវិធីសម្លេងយុត្តិធម៌ ។